ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១១ សរណន

# សារាចរណែនាំ

## ស្តីពី

## ការផ្អាកជាបណ្តោះអាសន្ននូវរាល់ការប្រឡងប្រជែងផ្ទៃក្នុង ដើម្បីប្តូរក្របខណ្ឌមន្ត្រីរាជការស៊ីវិល

កន្លងមករាជរដ្ឋាភិបាលពិនិត្យឃើញថា ក្រសួង ស្ថាប័នមួយចំនួនបានស្នើសុំធ្វើការប្រឡងប្រជែងផ្ទៃក្នុង ដើម្បីប្តូរប្រភេទក្របខណ្ឌរបស់មន្ត្រីរាជការ ដោយយកសញ្ញាប័ត្រតែមួយមុខគត់ធ្វើជាល័ក្ខខ័ណ្ឌសម្រាប់ការប្រឡងប្រជែង ដែលធ្វើឱ្យប៉ះពាល់ដល់ស្តង់ដារពីរ៉ាមីតនៃក្របខណ្ឌនីមួយៗ និងនាំឱ្យមានផលវិបាកដល់ការគ្រប់គ្រងក្របខណ្ឌមុខងារសាធារណៈ ។

ឈរលើស្មារតីនេះ ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការស៊ីវិល រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័នដូចខាងក្រោមៈ

១- ផ្អាកជាបណ្តោះអាសន្នរាល់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខណ្ឌ ដោយយកសញ្ញាប័ត្រតែមួយមុខគត់ធ្វើជាល័ក្ខខ័ណ្ឌ ។

២- ប្រគល់ភារកិច្ចឱ្យអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សហការជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងគ្រប់ក្រសួង ស្ថាប័នដើម្បីកំណត់គោលការណ៍អនុវត្តដូចខាងក្រោមៈ

- កំណត់ឱ្យបានច្បាស់ពីស្តង់ដារពីរ៉ាមីតតាមប្រភេទនៃក្របខណ្ឌនីមួយៗ
- កំណត់ចំនួនមុខតំណែងទំនេរនៃក្របខណ្ឌនីមួយៗប្រចាំឆ្នាំសម្រាប់ការប្រឡងប្រជែងប្តូរក្របខណ្ឌ
- រកដំណោះស្រាយដើម្បីធានាបានភាពត្រឹមត្រូវនៃសញ្ញាប័ត្រសម្រាប់ការប្រឡងប្រជែងប្តូរក្របខណ្ឌ
- រកដំណោះស្រាយចំពោះមន្ត្រីក្រមការ ដែលចេញពីសាលាភូមិន្ទរដ្ឋបាល ហើយមានសញ្ញាប័ត្រចាប់ពីបរិញ្ញាប័ត្រឡើងទៅដើម្បីប្រឡងប្រជែងប្តូរក្របខណ្ឌ
- រកមធ្យោបាយផ្តល់លទ្ធភាពដល់មន្ត្រីសកម្មការងារ ដែលពុំទាន់មានពេលវេលាគ្រប់គ្រាន់ទៅរៀនយក

សញ្ញាប័ត្រខ្ពស់ ឱ្យបានចូលរួមប្រឡងប្រជែងដើម្បីប្តូរក្របខណ្ឌ

- កំណត់មុខជំនាញវិជ្ជាជីវៈរបស់មន្ត្រីរដ្ឋបាលឱ្យបានច្បាស់លាស់
- រៀបចំយន្តការ នីតិវិធី និងបែបបទសម្រាប់ការប្រឡងប្រជែងផ្ទៃក្នុងដើម្បីប្តូរក្របខណ្ឌឱ្យមានស្តង់ដារគុណភាពខ្ពស់
- ចំពោះក្របខណ្ឌដែលផ្អែកលើជំនាញវិជ្ជាជីវៈច្បាស់លាស់ (គ្រូពេទ្យ គ្រូបង្រៀន អ្នកបច្ចេកទេស) ការប្តូរក្របខណ្ឌអាចប្រព្រឹត្តទៅបានលុះត្រាតែបានទៅបន្តការសិក្សាស្របតាមជំនាញវិជ្ជាជីវៈរបស់ខ្លួន ហើយបានទទួលសញ្ញាប័ត្រខ្ពស់ជាង ។

៣- ក្រោយពីបានកសាងគោលការណ៍សម្រាប់អនុវត្តខាងលើនេះរួចហើយ ត្រូវរៀបចំបែបបទសុំស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលដើម្បីដាក់ឱ្យអនុវត្ត ។

ទទួលបានសរាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន " ដើម្បីអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ